**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** ៖..៧៤..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន
# ឋបនីយជីវមណ្ឌលបឹងទន្លេសាប

៚✧៛

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការការពារបរិស្ថាននិង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៣៣ក្រ.ច ចុះថ្ងៃទី០៩ ខែមិនា ឆ្នាំ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ស្តីពីការបង្កើតនិងគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ ៥៧ អនក្រ /បកចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០១ ។

## សម្រេច :

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

បង្កើតលេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ឱ្យស្ថិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីជួយដល់ការសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និង សហការរវាងក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិ អាជ្ញាធរដែនដី និងសង្គមស៊ីវិល ក្នុងកិច្ចការការពារ និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព នៅក្នុងតំបន់ភូមិសាស្ត្រ និងដែនសមត្ថកិច្ច ដែលត្រូវបានប្រគល់ឱ្យ ។

**មាត្រា២.-**

លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប មានឋានៈស្មើនាយកដ្ឋាននៃបណ្ដាក្រសួង ដែលដឹកនាំដោយលេខាធិការ ១រូប មកពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងលេខាធិការរងមួយចំនួន មកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្នុងនោះ លេខាធិការរងមកពីក្រសួងបរិស្ថាន ទទួលបន្ទុកជាលេខាធិការរងអចិន្ត្រៃយ៍ ។

លេខាធិការដ្ឋានមានមន្ត្រីបំរើការងារមកពី ក្រុមសម្របសម្រួលបច្ចេកទេសបឹងទន្លេសាប ដែលកំពុងបំរើការងារឱ្យថបនីយជីវមណ្ឌលបឹងទន្លេសាប ។ ដោយផ្អែកលើផែនការប្រចាំឆ្នាំ លេខាធិការដ្ឋានអាចលើកសំណើជ្រើសរើសសមាជិកបន្ថែមពី ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

**មាត្រា៣.-**

ក្នុងការអនុវត្តការងារសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និងសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ក្នុងកិច្ចការពារ និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ត្រូវឱ្យមានផ្នែកបច្ចេកទេសមួយចំនួន ដែលជារចនាសម្ព័ន្ធ ជាអាទិ៍៖ ផ្នែកយុទ្ធសាស្ត្រនយោបាយ និងបណ្ដាញការងារ ផ្នែកសិក្សាស្រាវជ្រាវតាមដានត្រួតពិនិត្យ និងទិន្នន័យពត៌មាន ។

ផ្នែកនីមួយៗ មានថ្នាក់ស្មើនឹងការិយាល័យ ដែលដឹកនាំដោយប្រធាន និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

**មាត្រា៤.**_

លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ដែលជាសេនាធិការរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានភារកិច្ច :

- រៀបចំយុទ្ធសាស្ត្រ និងយន្តការ ដើម្បីសំរេចគោលបំណងសំខាន់ៗ របស់ថបនីយជីវមណ្ឌលបឹងទន្លេសាប
- បង្កើតប្រពន្ធ័គ្រប់គ្រងទិន្នន័យ ពត៌មានចម្រុះ សំរាប់ថបនីយជីវមណ្ឌលបឹងទន្លេសាប និង យន្តការផ្លាស់ប្តូរទិន្នន័យពត៌មាន ក្នុងចំណោមស្ថាប័នពាក់ព័ន្ធ
- តាមដានពិនិត្យ វាយតំលៃ និងធ្វើរបាយការណ៍ស្តីពីស្ថានភាពថបនីយជីវមណ្ឌលបឹងទន្លេសាប ក្នុងរយៈពេលពី ៤ ទៅ ១០ ឆ្នាំម្តង តាមតំរូវការចាំបាច់
- សម្របសម្រួល និងសហការជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យឡើងវិញ នូវច្បាប់ បទប្បញ្ញត្តិនានាដើម្បីធ្វើអនុសាសន៍លើកស្ទួយការគ្រប់គ្រង ថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព
- សម្របសម្រួលរៀបចំប្រព័ន្ធសិក្សាស្រាវជ្រាវ និងឃ្លាំមើលជីវចំរុះ
- បង្កើតបណ្តាញទំនាក់ទំនងជាមួយនឹងអាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្នុងគោលបំណងប្រមូលពត៌មាន សំរាប់បំរើដល់ការធ្វើផែនការស្នើសេចក្តីសំរេចចិត្ត និងការអនុវត្តផែនការអភិរក្ស និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប
- រៀបចំកិច្ចប្រជុំ ឬវេទិកាពិភាក្សា ដើម្បីពិភាក្សាលើបញ្ហា ដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប និងរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ
- សម្របសម្រួលជាមួយនឹងក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ក្នុងគោលបំណងរៀបចំ លើកគម្រោងផែនការ ដើម្បីរកជំនួយពីរាជរដ្ឋាភិបាល និងអន្តរជាតិ
- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ អំពីសកម្មភាពរបស់លេខាធិការដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាផ្តល់ឱ្យ ។

# ជំពូកទី ២

## អវសានប្បញ្ញត្តិ

**មាត្រា៥.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និង អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ